# ដំណឹងជ្រើសរើសបុគ្គលិក

មេហ្គាលីស៊ីង ភីអិលស៊ី
MEGA LEASING PLC.

មេហ្គាលីស៊ីង ភីអិលស៊ី គឺជាគ្រឹះស្ថានផ្តល់សេវាកម្មភតិសន្យាហិរញ្ញវត្ថុដែលត្រូវ បានបង្កើតឡើងនៅក្នុងឆ្នាំ ២០១៣ និងទទួលបានអាជ្ញាប័ណ្ណជាផ្លូវការ ពីធនាគារជាតិនៃកម្ពុជា នៅក្នុងខែមករា ឆ្នាំ ២០១៤។ បេសកកម្មរបស់គ្រឹះស្ថាន មេហ្គាលីស៊ីង ភីអិលស៊ី គឺផ្តល់សេវាកម្មហិរញ្ញវត្ថុឆាប់រហ័ស ដើម្បីឆ្លើយតបតាមតម្រូវការរបស់អតិថិជន ជាពិសេសទៅលើផលិតផលសម្រាប់ប្រើប្រាស់ និងសម្រាប់អាជីវកម្ម រួមមាន រថយន្តម៉ូតូ, កង់, ឧបករណ៍អេឡិចត្រូនិក គ្រឿងប្រើប្រាស់ក្នុងផ្ទះ គ្រឿងសង្ហារឹម និងឧបករណ៍ និងគ្រឿងចក្របម្រើឲ្យវិស័យកសិកម្ម។ ដើម្បីឆ្លើយតបនឹងការរីកចម្រើនរបស់ខ្លួន ក្រុមហ៊ុនត្រូវការជ្រើសរើសមុខតំណែងដូចព័ត៌មានលំអិតខាងក្រោម៖

**មុខតំណែង:** ហេរញ្ញិក (០៧)

**ទីតាំងជ្រើសរើស:** សាខាភ្នំពេញ(០១), ត្បូងឃ្មុំ(០១),កំពង់ចាម(០១), បាត់ដំបង (០១), បន្ទាយមានជ័យ (០១), សៀមរាប(០១) និងសាខាព្រះសីហនុ(០១)

**កាលបរិច្ឆេទឈប់ទទួលពាក្យ:** ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

## ភារកិច្ច និងការទទួលខុសត្រូវ៖

- ធ្វើបដិសណ្ឋារៈអតិជន និង ពន្យល់ណែនាំសម្របសម្រួលព្រមទាំងផ្សព្វផ្សាយពីផលិតផល និង សេវាកម្មរបស់ក្រុមហ៊ុនជូនអតិថិជន
- កត់ត្រាប្រតិបត្តិការសាច់ប្រាក់ចេញឬចូលប្រចាំថ្ងៃទៅក្នុងសៀវភៅសាច់ប្រាក់ និង នៅក្នុងសៀវភៅធានាគារ
- រាប់សាច់ប្រាក់ និង ផ្ទៀងផ្ទាត់ជាមួយសៀវភៅសាច់ប្រាក់ប្រចាំថ្ងៃ
- រៀបចំ និង រក្សាទុកឯកសារពាក់ព័ន្ធហិរញ្ញវត្ថុរបស់សាខារងឲ្យមានសណ្តាប់ធ្នាប់ និង សុវត្ថិភាព
- ត្រួតពិនិត្យសក្ខីប័ត្រមុខនឹងទទួល ឬ បញ្ចេញសាច់ប្រាក់ពីអតិថិជន និង មន្ត្រីឥណទាន
- ធ្វើការកត់ត្រារាល់ប្រតិបត្តិការប្រមូលសាច់ប្រាក់(Cash, Wing, and Bank)ទៅក្នុងប្រព័ន្ធកុំព្យូទ័រនៅតាមសាខា
- ចូលរួម និង ជួយបេឡាធិការ(cashier) សំរាប់ការដាក់ឬដកប្រាក់ពីធនាគារ
- ការងារមួយចំនួនផ្សេងទៀតដែលត្រូវបានចាត់ចែងដោយប្រធានផ្ទាល់ និងប្រធានសាខាខេត្ត

## លក្ខខណ្ឌជ្រើសរើស៖

1. បរិញ្ញាបត្រផ្នែកគណនេយ្យ រឺហិរញ្ញវត្ថុ រឺ ធនាគារ
2. មានបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យធនាគារ មីក្រូហិរញ្ញវត្ថុ(MFI) ឬភតិសន្យាហិរញ្ញវត្ថុ(ការបង់រំលស់) កាន់តែប្រសើរ
3. មានចំណេះដឹងផ្នែក កុំព្យូទ័រ និង ភាសាអង់គ្លេស, មានទំនាក់ទំនងល្អ និង ជំនាញធ្វើកាងារជាក្រុម
4. ចេះគ្រប់គ្រងបានយ៉ាងល្អនៅលើភារកិច្ចការងារពហុ/និងការងារដែលមានការកំណត់ ពេលវេលា ព្រមទាំងការងារដែលមាសម្ពាធ
5. មានទីលំនៅក្នុងតំបន់ប្រតិបត្តិការ ឬនៅជិតតំបន់ប្រតិបត្តិការជាអាទិភាព

ក្រុមហ៊ុន មេហ្គាលីស៊ីង ភីអិលស៊ី និងធ្វើការផ្តល់ប្រាក់បៀវត្សក្នុងលក្ខណៈប្រកួតប្រជែង និង មានកំណើនទៀងទាត់ប្រចាំឆ្នាំ។ មានផ្តល់ប្រាក់ឧបត្ថម្ភ ចូលឆ្នាំខ្មែរ និង បុណ្យភ្ជុំបិណ្ឌ, ប្រាក់លើកទឹកចិត្ត, ប្រាក់សោធននិវត្តន៍ ការធានារ៉ាប់រងសុខភាព និង គ្រោះថ្នាក់ 24 ម៉ោង , ធានារ៉ាប់រងអាយុជីវិត និង មានការឈប់សម្រាកស្របទៅតាមច្បាប់ការងាររួមទាំងអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត។

ប្រសិនបើបេក្ខជននិងបេក្ខនារីមានចំណាប់អារម្មណ៍ អាចផ្ញើប្រវត្តិរូបសង្ខេប និងលិខិតអម (CV and Cover letter) ព្រមទាំងថតចម្លងឯកសារដូចខាងក្រោម៖

- សញ្ញាបត្រដែលទទួលបាន ឬ លិខិតបញ្ជាក់ការសិក្សាពីសាកលវិទ្យាល័យ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ឯកសារដែលមានតំលៃស្មើ
- សៀវភៅគ្រួសារ និង សំបុត្របញ្ជាក់កំណើត

សូមផ្ញើមកកាន់នាយកដ្ឋានធនធានមនុស្ស មេហ្គាលីស៊ីង ភីអិលស៊ីតាមរយៈ អាស័យដ្ឋាន ផ្ទះលេខ៦៧ ផ្លូវលេខ១២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឬផ្ញើមកតាមរយៈ អ៊ីមែល៖ recruitment@megaleasing.com.kh ឬ ព័ត៌មានបន្ថែមអាចទាក់ទងតាមរយៈទូរសព្ទ៖ ០៦៩ ៣៦៤ ៦៦៦/០៦៩ ៦៤៤ ៨៨៨

សាខាខេត្តត្បូងឃ្មុំតាមរយៈ អាស័យដ្ឋាន ភូមិស្ទូងលិច, សង្កាត់សួង, ក្រុងសួង, ខេត្តត្បូងឃ្មុំ ទូរសព្ទ៖ ០៦៩ ៣២២ ៨៨៨

សាខាខេត្តកំពង់ចាម: ភូមិបឹងស្នាយ, សង្កាត់សំបូរមាស, ក្រុងកំពង់ចាម, ខេត្តកំពង់ចាម ទូរសព្ទ៖ ០៦៩ ៣២២ ៨៨៨

សាខាខេត្តសៀមរាប: ផ្ទះលេខ ៣១៤A, ផ្លូវលោកតាណឹយ,ក្រុមទី១១, ភូមិបន្ទាយចាស់, សង្កាត់ស្លក្រាម, ក្រុងសៀមរាប, ខេត្តសៀមរាប ទូរសព្ទ៖០៦៩ ៩៣០ ៦៦៦

សាខាខេត្តព្រះសីហនុ: ផ្លូវបុរីកម្មករ(សេតេ), ភូមិ២, សង្កាត់៣, ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ ទូរស័ព្ទ៖ ០៦៩ ៤៤០ ៤៤៤

សាខាខេត្តបន្ទាយមានជ័យ: ផ្ទះលេខ ៣៥០, ផ្លូវលេខ ៥៦A, សង្កាត់កំពង់ស្វាយ, ក្រុង សេរីសោភណ្ឌ, ខេត្តបន្ទាយមានជ័យ, ទូរស័ព្ទ៖ ០៦៩ ៦០០ ៨៨៨

សាខាខេត្តបាត់ដំបង: ផ្ទះលេខ ១២-១៣, ភូមិអូរតាគាំ១, សង្កាត់ទួលតាឯក, ក្រុងបាត់ដំបង, ខេត្តបាត់ដំបង ទូរស័ព្ទ៖ ០៦៩ ៩៨០ ៦៦៦

ធ្វើឲ្យជីវិតទាន់សម័យ